រាជបណ្ឌិត្យសភាកម្ពុជា

# ការគ្រប់គ្រងការបណ្តុះបណ្តាលគ្រូមត្តេយ្យ សិក្សានៃសាលាមធ្យមសិក្សាគរុកោសល្យ មត្តេយ្យមជ្ឈិម (២០១៦-២០២០)

# The Training Management of Kindergarten Teachers, Pre-School Teacher Training Center (2016-2020)

មាស សុខីណា

សារណាបរិញ្ញាបត្រជាន់ខ្ពស់

ជំនាញ : រដ្ឋបាលសាធារណៈ

២០២២

## រាជបណ្ឌិត្យសភាកម្ពុជា

# ការគ្រប់គ្រងការបណ្ដុះបណ្ដាលគ្រូមត្តេយ្យសិក្សានៃសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម (២០១៦-២០២០)

# The Training Management of Kindergarten Teachers, Pre-School Teacher Training Center (2016-2020)

ព្រះរាជាណាចក្រកម្ពុជា
បណ្ណាល័យ
លេខ 0.0.1.2.7.0 6
រាជបណ្ឌិត្យសភាកម្ពុជា

មាស សុខីណា
គ្រូណែនាំ : បណ្ឌិត ឌីត សំណាង

សារណាបរិញ្ញាបត្រជាន់ខ្ពស់

ជំនាញ : រដ្ឋបាលសាធារណៈ

ឆ្នាំ ២០២២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
រាជបណ្ឌិត្យសភាកម្ពុជា

Royal Academy of Cambodia
Académie Royale du Cambodge

**លេខ**: ០១៧ / **២៣ ស.ស.រ.**

# សេចក្តីសម្រេច

## ស្តីពី

## ការអនុញ្ញាតឱ្យការពារបញ្ចប់សារណាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

- បានឃើញព្រះរាជក្រឹត្យ នស/រកត/១២១៩/១៩៦២ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យ លេខ១២៤ អនក.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញសេចក្តីសម្រេចលេខ ១១ ស.ស.រ. ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការបណ្តុះបណ្តាលថ្នាក់ក្រោយបរិញ្ញាបត្របង់ថ្លៃសិក្សាស្រាវជ្រាវនៅរាជបណ្ឌិត្យសភាកម្ពុជា
- យោងគោលការណ៍ស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅរាជបណ្ឌិត្យសភាកម្ពុជា
- យោងចំណារឯកភាពរបស់គ្រូណែនាំចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៣

## សម្រេច

**ប្រការ ១** : អនុញ្ញាតឱ្យលោកស្រី **មាស សុខីណា** និស្សិត **ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី៧ វគ្គ១** ជំនាញ **រដ្ឋបាលសាធារណៈ** ការពារបញ្ចប់សារណានៅថ្ងៃទី_____ខែ_______ឆ្នាំ២០២_

**ប្រការ ២** : គណៈកម្មការវាយតម្លៃសារណា មជ្ឈមណ្ឌលបណ្តុះបណ្តាលនិងស្រាវជ្រាវ នៃរាជបណ្ឌិត្យសភាកម្ពុជា និងសាមីខ្លួនត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ ចន្ទ ៨រោច ខែ មាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០២៣
**ប្រធាន**

បណ្ឌិតសភាចារ្យ **សុខ ទូច**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
រាជបណ្ឌិត្យសភាកម្ពុជា

Royal Academy of Cambodia
Académie Royale du Cambodge

លេខ : ០១៦៨ /២៣ ឧ.ឧ.ន.

# លិខិតឧទ្ទេសនាម
## គណៈកម្មការវាយតម្លៃការការពារបញ្ចប់សារណា
## ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

| ល.រ. | គោត្តនាម និង នាម | ជំនាញ | តួនាទី |
|---|---|---|---|
| ១ | បណ្ឌិត **សយ រាសី** | រដ្ឋបាលសាធារណៈ | ប្រធាន |
| ២ | បណ្ឌិត **អ៊ុំ ប៉ុម** | រដ្ឋបាលសាធារណៈ | គ្រូវាយតម្លៃទី១ |
| ៣ | បណ្ឌិត **សឿន សោភ័ណ** | រដ្ឋបាលសាធារណៈ | គ្រូវាយតម្លៃទី២ |
| ៤ | បណ្ឌិត **ឆាម រតនៈ** | រដ្ឋបាលសាធារណៈ | គ្រូវាយតម្លៃទី៣ |
| ៥ | បណ្ឌិត **ឌីត សំណាង** | រដ្ឋបាលសាធារណៈ | គ្រូណែនាំ |

- និស្សិត : **មាស សុខីណា** - **ភេទ : ស្រី**
- ជំនាញ : **រដ្ឋបាលសាធារណៈ** - **ជំនាន់ទី៧ វគ្គ១**
- ប្រធានបទ : **ការគ្រប់គ្រងការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សានៃសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម(២០១៦-២០២០)**
- គ្រូណែនាំ : បណ្ឌិត **ឌីត សំណាង**
- កាលបរិច្ឆេទការពារ : ថ្ងៃទី______ខែ______ឆ្នាំ២០២___ - ម៉ោង : ______________

ថ្ងៃចន្ទ ៨រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០២៣
ប្រធាន

បណ្ឌិតសភាចារ្យ **សុខ ទូច**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រធានបទ៖ ការគ្រប់គ្រងការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា នៃសាលាមធ្យមសិក្សាគរុកោសល្យ មត្តេយ្យមជ្ឈិម (២០១៦-២០២០)

បញ្ជាក់ថា៖ បេក្ខជននិស្សិត មាស សុខីណា
ពិតជាបានការពារសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដោយជោគជ័យ នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ ប្រាកដមែន។

| | |
|---|---|
| ១. លោកបណ្ឌិត **សយ រាសី** | ប្រធានគណៈកម្មការ |
| ២. លោកបណ្ឌិត **អ៊ុំ ប៊ុម** | គ្រូវាយតម្លៃទី១ |
| ៣. លោកបណ្ឌិត **សឿន សោភ័ណ** | គ្រូវាយតម្លៃទី២ |
| ៤. លោកបណ្ឌិត **ឆាម រតនៈ** | គ្រូវាយតម្លៃទី៣ |
| ៥. លោកបណ្ឌិត **ឌឹត សំណាង** | គ្រូណែនាំ |

**អគ្គលេខាធិការរង**
**ទទួលបន្ទុកមជ្ឈមណ្ឌលបណ្តុះបណ្តាលនិងស្រាវជ្រាវ**

**ស្មូត្រ សំណាង**

ព្រះរាជាណាចក្រកម្ពុជា
ប្រធានរាជបណ្ឌិត្យសភាកម្ពុជា
រាជបណ្ឌិត្យសភា

**បណ្ឌិតសភាចារ្យ សុខ ទូច**

# មាតិកា


ឧទ្ទិសស្នាដៃ ........ I

សេចក្តីថ្លែងអំណរគុណ ........ II

អំណះអំណាង ........ III

មូលន័យសង្ខេបជាភាសាខ្មែរ ........ IV

មូលន័យសង្ខេបជាភាសាអង់គ្លេស ........ VI

តារាងអក្សរកាត់ ........ VIII

អារម្ភកថា ........ IX


## សេចក្តីផ្តើម


១.លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

២.ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ៣

៣.គោលបំណងនៃការស្រាវជ្រាវ ........ ៤

៤.ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ៥

៥.វិធីសាស្រ្តនៃការស្រាវជ្រាវ ........ ៦

៦.សារៈសំខាន់នៃការស្រាវជ្រាវ ........ ១២

៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ១៣


## ជំពូកទី១

## ទស្សនទានស្តីពីការគ្រប់គ្រងការបណ្តុះបណ្តាលគរុសិស្សមត្តេយ្យសិក្សា


**១.១.បញ្ញត្តិនៃពាក្យ ការគ្រប់គ្រង និង ការបណ្តុះបណ្តាល** ........ ១៤

**១.២.បទបញ្ញត្តិ និងលក្ខខណ្ឌនៃការបណ្តុះបណ្តាល** ........ ២៣

**១.៣.តួនាទី និងភារកិច្ចនៃការបណ្តុះបណ្តាល** ........ ២៦

**១.៤.កម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា** ........ ២៧

១.៤.១.គោលបំណងនៃកម្មវិធីបណ្តុះបណ្តាល ............................................ ២៩
១.៤.២. រចនាសម្ព័ន្ធនៃកម្មវិធីបណ្តុះបណ្តាល ............................................ ៣០

## ជំពូកទី២

## ដំណើរការគ្រប់គ្រងការបណ្តុះបណ្តាលគ្រូបង្រៀនមត្តេយ្យសិក្សា

**២.១.ស្ថានភាពនៃសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម** ................. ៣២
**២.២.រចនាសម្ព័ន្ធគ្រប់គ្រង** ........................................................................ ៣៣
២.២.១.ស្ថានភាពបុគ្គលិក ........................................................................ ៣៥
២.២.២.តួនាទី និងភារកិច្ច ........................................................................ ៣៧
២.២.៣.ស្ថានភាពគរុសិស្ស ........................................................................ ៤២
២.២.៤.ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ........................................................ ៤៦
**២.៣.ផែនការយុទ្ធសាស្ត្រ** ........................................................................ ៤៩
**២.៤.ការជ្រើសរើសសិស្សឱ្យចូលរៀន** ........................................................ ៥១
**២.៥.ការបណ្តុះបណ្តាល** ........................................................................ ៥៤
២.៥.១.ការអនុវត្តកម្មវិធីបណ្តុះបណ្តាលឆ្នាំ២០១៦-២០២០.......................... ៥៦
២.៥.២.ការចុះកម្មសិក្សាគរុកោសល្យឆ្នាំ២០១៦-២០២០.............................. ៥៩
២.៥.៣.លទ្ធផលបណ្តុះបណ្តាលឆ្នាំ២០១៦-២០២០.......................................... ៦៦
**២.៦.ការផ្លាស់ប្តូរប្រព័ន្ធនៃការបណ្តុះបណ្តាល** ........................................ ៧៣
**២.៧.វិធានការពង្រឹងគុណភាពនៃការបណ្តុះបណ្តាល** .................................. ៧៥

## ជំពូកទី៣

## ការបកស្រាយទិន្នន័យការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា

**៣.១.ប្រសិទ្ធភាពនៃការគ្រប់គ្រងការងារបណ្តុះបណ្តាល**................................ ៧៧
**៣.២.ការរៀបចំកម្មវិធីបណ្តុះបណ្តាល** ........................................................ ៩៣
៣.២.១.កម្មវិធីបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា គ្រូបឋមសិក្សា

៣.២.២.កម្មវិធីបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា គ្រូមធ្យមសិក្សា
**៣.៣.គន្លាប្រឈមនៃការបណ្តុះបណ្តាលគរុសិស្សមត្តេយ្យសិក្សា** ..................... ៩៩
៣.៣.១.គ្រូឧទ្ទេស ..................................................................................... ៩៩
៣.៣.២.គរុសិស្ស ..................................................................................... ១០០
៣.៣.៣.កម្មវិធីសិក្សា ..................................................................................... ១០០
៣.៣.៤.វិធីសាស្ត្របង្រៀន និងការកសាងសម្ភារសិក្សា ..................................... ១០១
៣.៣.៥.ការអនុវត្តកម្មសិក្សាគរុកោសល្យ ..................................................... ១០២
**៣.៤.ដំណោះស្រាយលើការបណ្តុះបណ្តាលគរុសិស្សមត្តេយ្យសិក្សា** ............... ១០២
៣.៤.១.គ្រូឧទ្ទេស ..................................................................................... ១០៣
៣.៤.២.គរុសិស្ស ..................................................................................... ១០៣
៣.៤.៣.កម្មវិធីសិក្សា ..................................................................................... ១០៤
៣.៤.៤.វិធីសាស្ត្របង្រៀន និងការកសាងសម្ភារសិក្សា ..................................... ១០៤
៣.៤.៥.ការអនុវត្តកម្មសិក្សាគរុកោសល្យ ..................................................... ១០៥
**សេចក្តីសន្និដ្ឋាន**
**អនុសាសន៍**
**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**
- ឧបសម្ព័ន្ធ១ ៖ កម្រងសំណួរ
- ឧបសម្ព័ន្ធ២ ៖ របាយម៉ោងតាមមុខវិជ្ជានីមួយៗសម្រាប់បណ្តុះបណ្តាលឆ្នាំទី១ ឆ្នាំទី២
- ឧបសម្ព័ន្ធ៣ ៖ ស្ថិតិគរុសិស្សដែលបានបណ្តុះបណ្តាលកន្លងមកពីឆ្នាំ១៩៨៧-២០២០
- ឧបសម្ព័ន្ធ៤ ៖ មុខវិជ្ជាបណ្តុះបណ្តាលប្រចាំឆ្នាំសិក្សា២០១៩ និង២០២០
- ឧបសម្ព័ន្ធ៥ ៖ រូបថតសកម្មភាពបណ្តុះបណ្តាលទាំង៦

# មូលន័យសង្ខេបជាភាសាខ្មែរ

សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម មានទីតាំងស្ថិតនៅអគារលេខ ២០១ មហាវិថីព្រះនរោត្តម ក្នុងសង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ និងស្ថិតនៅក្រោមឱវាទផ្ទាល់របស់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានបង្កើតឡើង នៅក្នុងឆ្នាំ១៩៨៥ ចាប់ផ្តើមបើកដំណើរការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាដែលមកពី២៥ រាជធានី ខេត្ត ក្រុង ទូទាំងប្រទេសកម្ពុជានៅឆ្នាំ១៩៨៧។

ការសិក្សាស្រាវជ្រាវប្រធានបទនេះ មានគោលបំណងស្វែងរកចំណុចខ្វះខាតលើកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាល គុណវុឌ្ឍិរបស់គ្រូឧទ្ទេស វិធីសាស្ត្រ និងការផលិតសម្ភារៈបង្រៀន ការចុះកម្មសិក្សាគរុកោសល្យ និងការប្រឡងជ្រើសរើសសិស្សឱ្យចូលរៀន របស់សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម ព្រមទាំងពិនិត្យលទ្ធផល និងសមត្ថភាពរបស់គរុសិស្សនៅក្នុងពេលបណ្តុះបណ្តាលរយៈពេល២ឆ្នាំ ដោយផ្អែកលើទិន្នន័យ២ គឺទី១ទិន្នន័យអង្កេត ឬទិន្នន័យចម្បង (Primary Data) ដែលទិន្នន័យទាំងអស់នេះទទួលបានពីអ្នកចូលរួមផ្តល់ចម្លើយ តាមរយៈការសម្ភាសន៍ដោយផ្ទាល់មាត់ជាមួយថ្នាក់គ្រប់គ្រង គ្រូឧទ្ទេស និងគរុសិស្ស ដែលកំពុងបម្រើការងារ និងបណ្តុះបណ្តាលនៅសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម។ ទី២ ទិន្នន័យដែលមានស្រាប់ (Secondary Data) តាមរយៈរបាយការណ៍វាយតម្លៃ ឬរបាយការណ៍បូកសរុប ឯកសារវាយតម្លៃទាក់ទងការពង្រឹងគុណភាព ចំណុចខ្លាំង ចំណុចខ្សោយ បញ្ហាប្រឈម ដំណោះស្រាយ និងឯកសារផ្សេងៗទៀតទាក់ទងនឹងទស្សនៈ ការគ្រប់គ្រងការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា ព្រមទាំងស្ថិតិ ការសម្ភាសន៍ និងគេហទំព័ររបស់ក្រសួងពាក់ព័ន្ធមួយចំនួន។

សារណានេះ មានប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវច្រើនយ៉ាង ដើម្បីស្វែងរកអំណះអំណាង មកធ្វើជាទឡ្ហីកម្មឱ្យមានលក្ខណៈវិទ្យាសាស្ត្រ ដូចជាវិធីសាស្ត្រស្រាវជ្រាវបែបបរិមាណវិស័យ(Quantitative Method) និងគុណវិស័យ(Qualitative Method) ដោយយោងលើគំរូសំណាកវិធីសាស្ត្រមិនចៃដន្យ មានការបង្ហាញ ការវិនិច្ឆ័យ សមល្មមតាមលទ្ធភាព និងពេលវេលាខ្លី និងមានភាពបត់បែន។

ការសិក្សាត្រូវបានបកស្រាយមាន៣ជំពូកៈ ជំពូកទី១ ទស្សនទានស្តីពីការគ្រប់គ្រងការបណ្តុះបណ្តាលគរុសិស្សមត្តេយ្យសិក្សា ឆ្លុះបញ្ចាំងពីបទបញ្ញត្តិ លក្ខខណ្ឌបណ្តុះបណ្តាល ព្រមទាំងគោលបំណង និងរចនាសម្ព័ន្ធនៃកម្មវិធី។ ជំពូក២ ដំណើរការគ្រប់គ្រងការបណ្តុះបណ្តាលគ្រូ

បង្រៀនមត្តេយ្យសិក្សា ប្រវត្តិរបស់សាលា ស្ថានភាព និងលទ្ធផលអនុវត្តការងារបណ្តុះបណ្តាល សកម្មភាពទាំង៦ ការចុះកម្មសិក្សាគរុកោសល្យរបស់គរុសិស្ស និងការផ្លាស់ប្តូររូបមន្តនៃការប្រឡងជ្រើសរើសសិស្សឱ្យចូលរៀនផែនការយុទ្ធសាស្រ្ត ព្រមទាំងវិធានការផ្សេងៗចូលរួមពង្រឹងគុណភាពបណ្តុះបណ្តាល។ ជំពូកទី៣ យើងនឹងធ្វើការបកស្រាយលទ្ធផលការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា តាមរយៈការវិភាគលើកម្រងសំណួរដែលបានធ្វើការសម្ភាសន៍ជាមួយគណៈគ្រប់គ្រង គ្រូឧទ្ទេស និងគរុសិស្ស ចំនួន១០០នាក់(គណៈគ្រប់គ្រង៣នាក់ គ្រូឧទ្ទេស១៣នាក់ និង គរុសិស្ស៨៤នាក់)។

ការស្រាវជ្រាវមានសេចក្តីសន្និដ្ឋាន ដែលបានបង្ហាញឱ្យឃើញពីដំណោះស្រាយបញ្ហាខ្វះខាត ដែលជាកត្តាធ្វើឱ្យការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាប្រកបដោយគុណភាព និងប្រសិទ្ធភាព។ ដូចនេះក្រោយពីបញ្ចប់ការបណ្តុះបណ្តាលរយៈពេលពីរឆ្នាំ គរុសិស្សនឹងក្លាយជាគ្រូមត្តេយ្យសិក្សាប្រកបដោយស្មារតីវិជ្ជាជីវៈ ដែលមានសមត្ថភាពគ្រប់គ្រាន់ សម្រាប់ប្រើប្រាស់ក្នុងការបង្រៀនកុមារនៅតាមសាលាមត្តេយ្យសិក្សាមូលដ្ឋាន ព្រមទាំងមានអនុសាសន៍សម្រាប់ជួយកែលម្អ និងពង្រឹងគុណភាព នៃការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាឱ្យកាន់តែល្អប្រសើរឡើង។